01355871

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 12 / 2016
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ចន្ទ ទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦

## សវនាការលើភស្តុតាង - ថ្ងៃ ៤៨៣

រៀបចំដោយ៖ លោកស្រី សែ កុលវុឌ្ឍី និង លោក Roger PHILLIPS

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរ, ចៅក្រម Claudia FENZ |
| ចៅក្រមបំរុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង លាង, លោក William SMITH |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អារុណ, លោក លីវ សុវណ្ណ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក វ៉ែន ពៅ, លោក ឡោ ជុនធី |

| |
|---|
| ដើមបណ្តឹង/សាក្សី/អ្នកជំនាញ៖ លោកស្រី ប៊ិត បឿន (2-TCW-953), លោកស្រី សុក សុជាតា (មេធាវីប្រឹក្សាសាក្សី) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោកស្រី សួរ សុទ្ធាវី |
| ផ្សេងៗ៖ លោក កែវ រ៉ាត, លោក ឡុញ ង៉ែត, កញ្ញា ស្រី ណាក់, លោក រ៉ាត សុម៉ៅ, កញ្ញា Tereza TUPA |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ | ចាប់ផ្តើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៤.៣៨ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១៦ | បញ្ចប់ម៉ោង៖ ១០.៣៣ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៤០ | បញ្ចប់ម៉ោង៖ ១៣.៣១ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៣ ម៉ោង និង ២៦ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៥ | ០៩.០៦ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | អង្គជំនុំជម្រះ | ០៩.០៦ | ០៩.០៧ |
| សេចក្តីសម្រេចផ្ទាល់មាត់លើការទទួលយកឯកសារ | អង្គជំនុំជម្រះ | ០៩.០៧ | ០៩.១៣ |
| ការតាំងសំណួរទៅសាក្សី ប៊ិត បឿន (2-TCW-953) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.១៣<br>០៩.២២<br>១៣.៣២ | ០៩.២២<br>១១.៤០<br>១៤.៣៧ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគី

ទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

__សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ__

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

__សេចក្តីសម្រេចផ្ទាល់មាត់ស្តីពីការទទួលយកចម្លើយពីមុន និង ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយសាក្សី 2-TCW-953__

អនុលោមតាមសេចក្តីណែនាំថ្មីដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបង្កើតឡើង សម្រាប់ការស្នើសុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤, កាលពីថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិបានផ្ញើឯកសារ D114/183 ដែលជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី 2-TCW-953 មកអង្គជំនុំជម្រះសាលាដំបូង និង ភាគីផ្សេងទៀត តាមរយៈអ៊ីមែល។ សាក្សីរូបនេះត្រូវបានកំណត់ពេលឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ នៅក្នុងប្រធានបទសវនាការស្តីពីតួនាទីរបស់ជនជាប់ ចោទ។ បន្ទាប់មកទៀត សហព្រះរាជអាជ្ញាអន្តរជាតិក៏បានផ្ញើខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយនេះ (ឯកសារ D114/183R) ជូនភាគី និង អង្គជំនុំជម្រះផងដែរ។ នៅថ្ងៃទី ៧ ខែ វិច្ឆិកា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុញ្ញាតតាមរយៈអ៊ីមែល ឱ្យដាក់បង្ហាញឯកសារ D114/183 និង D114/183R ដល់ភាគីក្នុងសំណុំរឿង ០០២ ហើយបន្ទាប់មកបានចេញដីកាសម្រេចជាផ្លូវការនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦ (ឯកសារ D100/40)។

អង្គជំនុំជម្រះរម្លឹកអំពីការអនុវត្តរបស់ខ្លួន ក្នុងការទទួលយកចម្លើយមុនៗទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឬ សាក្សី ដែលមកផ្តល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ហើយថា ការណ៍ដែលអង្គជំនុំជម្រះ និង ភាគីអាចចូលពិនិត្យចម្លើយទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី និង សាក្សីដែលនឹងត្រូវផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ គឺជាប្រយោជន៍នៃការស្វែងរកការពិត (ឯកសារ E363/3 កថាខណ្ឌ ២៥)។ ហេតុនេះ តាមការផ្តួចផ្តើមរបស់ខ្លួន អង្គជំនុំជម្រះសម្រេចទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយពីមុនរបស់សាក្សី 2-TCW-953 គឺឯកសារ D114/183 ហើយដាក់លេខជាឯកសារ E3/10721។

អង្គជំនុំជម្រះក៏រម្លឹកផងដែរអំពីសេចក្តីសម្រេចរបស់ខ្លួននាពេលថ្មីៗនេះថា ជាទូទៅអង្គជំនុំជម្រះនឹងមិនទទួលយករាល់ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយទាំងអស់មកធ្វើជាភស្តុតាងនោះទេ។ អង្គជំនុំជម្រះអាចទទួលយកជាភស្តុតាងនូវផ្នែកពាក់ព័ន្ធជាក់លាក់នៃខ្សែអាត់សំឡេង នៅពេលដែលភាគីចង្អុលបង្ហាញ

01355874



ចំណុចមិនស៊ីសង្វាក់គ្នារវាងខ្សែអាត់សំឡេង និង កំណត់ហេតុនៃការស្ដាប់ចម្លើយ (ឯកសារ E441/2 កថាខណ្ឌ ១៧)។ ដោយសារពុំមានការចង្អុលបង្ហាញចំណុចមិនស៊ីសង្វាក់គ្នារវាងខ្សែអាត់សំឡេង និង កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី 2-TCW-953 អង្គជំនុំជម្រះនឹងមិនទទួលយកឯកសារ D114/183R ជាភស្តុតាង នៅដំណាក់កាលនេះទេ។

<u>ការតាំងសំណួរទៅសាក្សី ប៊ិត បឿន (2-TCW-953)</u>

ប្រធានអង្គជំនុំជម្រះបានតាំងសំណួរបឋមមួយចំនួនទៅសាក្សី ព្រមទាំងប្រាប់អំពីសិទ្ធិ និងករណីយកិច្ច ដល់សាក្សី ប៊ិត បឿន (2-TCW-953) បន្ទាប់មកសហព្រះរាជអាជ្ញា មេធាវីការពារក្ដី ខៀវ សំផន បានតាំងសំណួរទៅសាក្សី។

## Newly Admitted Documents

| *TC No* | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/10721 | D114/183 | 01213579-01213609<br>01300034-01300056 | Written Record of Interview of [2-TCW-953] | C | 01213585<br>01213595<br>01213597<br>01213598<br>01213599<br>01213600<br>01213593<br>01213604<br>01213604 | 01300038<br>01300045<br>01300047<br>01300048<br>01300048<br>01300049<br>01300044<br>01300052<br>01300052 | / |

## Reclassified Documents

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/5647 | / | 00054371-<br>00054427<br>00640136-<br>00640186<br>00332559-<br>00332600 | DC-Cam Interview with Pet Na | P | 00054410<br>00054389-<br>00054390<br>00054389-<br>00054390<br>00054420-<br>00054421<br>00054415<br>00054424-<br>00054425<br>00054413<br>00054387<br>00054389<br>00054381 | 00640171<br>00640152<br>00640152<br>00640180-<br>00640182<br>00640175-<br>00640176<br>00640184<br>00640174<br>00640150<br>00640151<br>00640144-<br>00640145 | 00332588<br>00332572<br>00332572-<br>00332573<br>00332595-<br>00332596<br>00332592<br>00332598-<br>00332599<br>00332590<br>00332557<br>00332572<br>00332566 |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/2376 | D108/50/1.74<br>D91/1 | 00191296-<br>00191815<br>00192169-<br>00192666<br>00236900-<br>00237256 | Book by NAYAN Chanda entitled "Brother Enemy: The War after the War" | P | 00191354 | 00192228 | 00237647 |
| E3/562 | D108/28.240 | 00249989-<br>00249994<br>S00010558-<br>00010569<br>00280373-<br>00280388 | International Media Report "Phnom Penh Rally Marks 17th April Anniversary" | P | 00249989-<br>00249990<br>00249992 | S00010563<br>S00010565 | 00280379-<br>00280380<br>00280383 |

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៧)
- សេចក្ដីសម្រេចផ្ទាល់មាត់ទទួលយកឯកសារ E3/10721 ជាឯកសារភ័ស្តុតាង (០៩.១២)
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឲ្យបានមុនម៉ោង ៩.០០

| ព្រឹកនៅថ្ងៃអង្គារ ទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦។ (១៤.៣៨) |
|---|

| <u>កាលវេលាសវនាការបន្ត</u> |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

លោកស្រី សែ... លោក Roger PHILLIPS